ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋាន

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែកញ្ញា និងទិសដៅការងារខែតុលា ឆ្នាំ២០១៤

នៅក្នុងខែកញ្ញានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្ម លើការដ្ឋានជាច្រើន ដោយផ្សារភ្ជាប់បទដ្ឋានការងាររដ្ឋបាល បច្ចេកទេស នីតិវិធី និងហិរញ្ញវត្ថុ ជាពិសេសការរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ បន្តសម័យប្រជុំពេញអង្គ លើកទី៩ រៀបចំវេទិកាតាមភូមិភាគ ដំណើរការនីតិវិធីច្បាប់ស្តីពីថវិកាឆ្នាំ២០១៥ ការងារកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងសកម្មភាពការងារសង្គម និងខិតខំពង្រឹងពង្រីកភាពសុខដុមផ្ទៃក្នុង បង្កើនការសន្សំសំចៃខ្ពស់ បង្កើតសេវាថ្មីៗ កសាងគោលនយោបាយនានា បង្កើនកិច្ចសហប្រតិបត្តិការជាតិ អន្តរជាតិ និងបំពេញការងារសំខាន់ៗមួយចំនួនទៀតដូចខាងក្រោម៖

## I.លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា៖

-បានចាត់ចែងរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ចំនួន០២លើក ប្រជុំពេញអង្គ ព្រឹទ្ធសភា លើកទី៩ នីតិកាលទី៣ ចំនួន០២លើក ប្រជុំពិភាក្សាការងារជាមួយថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន ជួបពិភាក្សាការងារជាមួយលេខាស្ថានទូតជប៉ុន និងចូលរួមប្រជុំពិភាក្សាការងារផ្សេងៗ ព្រមទាំងបាន ពិនិត្យសម្រេចលើឯកសារចំនួន៦១០ច្បាប់ ។

### ១.សេវាទ្រទ្រង់មុខងារនីតិកម្ម៖

-បានរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ចំនួន០២លើក ដើម្បី៖ ពិនិត្យ និងសម្រេចសំណើរបស់គណបក្ស សម រង្ស៊ី ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៤ និងសំណើរបស់គណបក្សប្រជាជនកម្ពុជា លេខ:៩៤៦ លគ.គក ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៤ ស្នើសុំបោះឆ្នោតជ្រើសរើសសមាជិកគណៈកម្មការថ្មី (គណៈកម្មការទី១០) និងបំពេញសមាជិកក្នុងគណៈកម្មការទី១, ទី៣,ទី៦, ទី៧,ទី៨ និងគណៈកម្មការទី៩ ព្រឹទ្ធសភា ឯកភាពយល់ព្រមតាមសំណើរបស់សមាជិកព្រឹទ្ធសភាមកពីគណបក្ស សម រង្ស៊ី ដែលស្នើសុំចូលជាសមាជិកក្រុមនានា របស់ព្រឹទ្ធសភា នីតិកាលទី៣ ឯកភាពយល់ព្រមលើសេចក្តីព្រាងសេចក្តីសម្រេច ស្តីពីតួនាទី ភារកិច្ច និងសមត្ថកិច្ច របស់គណៈកម្មការ

អង្កេត ឃោសនា និងប្រឆាំងអំពើពុករលួយ ។

-រៀបចំប្រជុំពេញអង្គព្រឹទ្ធសភាចំនួន០២លើក ដើម្បី៖ បោះឆ្នោតជ្រើសតាំងសមាជិកគណៈកម្មការថ្មី (គណៈកម្មការទី១០) និងបោះឆ្នោតជ្រើសរើសបំពេញសមាជិកគណៈកម្មការទី១, ទី៣, ទី៦, ទី៧, ទី៨ និងគណៈកម្មការទី៩ ព្រឹទ្ធសភា និងបោះឆ្នោតជ្រើសតាំងសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមចំនួន០១រូប ។

**២.សេវាទទួលខុសត្រូវផ្នែកត្រួតពិនិត្យ៖**

-បានចុះបំពេញការងារអមជាមួយគណៈកម្មការទី៨ របស់ព្រឹទ្ធសភា ក្នុងជំនួបសវនាការជាមួយក្រសួងសុខាភិបាល ដើម្បីពិភាក្សាអំពីគម្រោងរៀបចំសិក្ខាសាលា ស្តីពីការវិវត្តនៃសេចក្តីព្រាងច្បាប់ស្តីពីការត្រួតពិនិត្យផលិតផលគ្រឿងស្រវឹង ។

**៣.សេវាទទួលខុសត្រូវផ្នែកតំណាង៖**

-បានរៀបចំវេទិកាសាធារណៈ ចំនួន០៥លើក ជាមួយក្រុមប្រឹក្សាឃុំ-សង្កាត់ និងប្រជាពលរដ្ឋ នៅខេត្តប៉ៃលិន ត្បូងឃ្មុំ កណ្តាល ព្រះវិហារ និងខេត្តស្វាយរៀង ស្តីពីការអនុវត្តគោលនយោបាយវិមជ្ឈការ វិសហមជ្ឈការ ព្រឹទ្ធសភា និងការពង្រឹងតួនាទី ភារកិច្ច របស់ក្រុមប្រឹក្សាឃុំ ក្នុងការអភិវឌ្ឍមូលដ្ឋាន សេវាសាធារណៈ មូលនិធិថវិកាអភិវឌ្ឍន៍ គោលនយោបាយភូមិ-ឃុំ មានសុវត្ថិភាព និងសមភាពយេនឌ័រ។

-បានទទួលពាក្យបណ្តឹងចំនួន០២ករណី និងបានបញ្ជូនលិខិតទៅស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធដោះស្រាយបានចំនួន០១ករណី ។

-រៀបចំបែបបទ និងអមដំណើរថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ចុះទៅតាមបណ្តាខេត្ត រាជធានីទូទាំងប្រទេសចំនួន៧៦លើក ដើម្បីចុះជួប និងជួយប្រជាពលរដ្ឋជួបគ្រោះមហន្តរាយខ្យល់ព្យុះ (បាក់ផ្ទះ) និងភ្លើងឆេះផ្ទះ ជួបពិភាក្សាការងារ សាកសួរសុខទុក្ខសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ-ឃុំ មានសុវត្ថិភាព ស្វែងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការ និងពិធីផ្សេងៗសរុបចំនួន៨២លើក ។

**៤.សេវាទទួលខុសត្រូវផ្នែកព័ត៌មាន៖**

-បានអមដំណើរសមាជិក-សមាជិកា គណៈកម្មការទី៨ព្រឹទ្ធសភា ចុះបំពេញបេសកកម្មទៅខេត្តបាត់ដំបង ដើម្បីទស្សនកិច្ចសិក្សា នៅគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ។

-មន្ត្រីរាជការបានចុះបេសកកម្ម ចំនួន០២លើក ដើម្បីរៀបចំវេទិកា, ពិភាក្សាការងារជាមួយ

នាយករដ្ឋបាលសាលាខេត្ត និងមន្ទីរពាក់ព័ន្ធ នៅខេត្តប៉ៃលិន កំពង់ធំ ព្រះវិហារ ត្បូងឃ្មុំ កណ្ដាល និងខេត្តស្វាយរៀង ។

**៥.ការងារអន្តរជាតិៈ**

-រៀបចំបែបបទជូនគណៈប្រតិភូព្រឹទ្ធសភា ទៅចូលរួមមហាសន្និបាតអន្តរសភា (AIPA) លើកទី៣៩ ស្ដីពីការពង្រឹងកិច្ចសហប្រតិបត្តិការសភា ក្នុងការកសាងសហគមន៍អាស៊ាន នៅប្រទេសឡាវ។

-ការងារវិទ្យាស្ថានសភាកម្ពុជា មានលទ្ធផលថ្មី (ជំនួយ Sweeden, Swiss, រដ្ឋសភាបារាំង) និងការងារ PBO (សហគមន៍អឺរ៉ុប, ធនាគារពិភពលោក ) ។

-ទំនាក់ទំនងជាមួយដៃគូអន្តរជាតិនានា (ឥណ្ឌា ប្រ៊ុយណេ ហ្វីលីពីន ឥណ្ឌូនេស៊ី ម៉ាឡេស៊ី វៀតណាម ថៃ រុស្ស៊ី អាល្លឺម៉ង់ អូស្ត្រាលី ស្ថានកុងស៊ុលបែលហ្ស៊ិក ស្ថានកុងស៊ុលន័រវែស ) ដើម្បីសុំអាហារូបករណ៍ និងទស្សនកិច្ចសិក្សា ។

**៦.ទំនាក់ទំនងសាធារណៈៈ**

-ទំនាក់ទំនងជាមួយស្ថានីយទូរទស្សន៍ជាតិ ទូរទស្សន៍អាស៊ីអាគ្នេយ៍ ដើម្បីផ្សព្វផ្សាយសមិទ្ធផលនានារបស់ព្រឹទ្ធសភា និងសាកលវិទ្យាល័យ CUS, CMTC, CDC, AEU, ECCC, CWF, NIDA, Hong kong Center សាកលវិទ្យាល័យមេគង្គកម្ពុជា សាកលវិទ្យាល័យន័រតុន និងចំរើនពហុបច្ចេកវិទ្យា ដើម្បីសុំអាហារូបករណ៍ និងទស្សនកិច្ចសិក្សា ។

-បានទទួលមន្ត្រីរាជការ សិស្ស និស្សិត សាធារណជន ចូលអានសៀវភៅ ចំនួន២៩២នាក់ ។

**៧.ការអភិវឌ្ឍន៍ធនធានមនុស្សៈ**

-បើកវគ្គបណ្ដុះបណ្ដាលក្នុងប្រទេសចំនួន០៩វគ្គ ស្ដីពីការថតរូប វគ្គClimate Change, Energy and Environment វគ្គInternational Trade and Investment Law វគ្គប្រព័ន្ធដឹកជញ្ជូននៃទីក្រុង វគ្គរបៀបសរសេរលិខិត Business Writing in ASEAN វគ្គថែទាំ និងជួសជុលកុំព្យូទ័រ វគ្គAdobe Premiere វគ្គភាសាជប៉ុន (ក្រុម១ ជំហាន៧ និងក្រុម២ ជំហាន២) ។

-ទទួលបានអាហារូបករណ៍ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ពីសាកលវិទ្យាល័យជាតិគ្រប់គ្រង ឆ្នាំសិក្សាឆ្នាំ២០១៨-២០១៩ ចំនួន០២នាក់ ។

-មន្ត្រីចំនួន០១រូប ចូលរួមវគ្គបណ្ដុះបណ្ដាល ស្ដីពីផែនការអភិវឌ្ឍន៍មនុស្ស នៅប្រទេសម៉ាឡេស៊ី មន្ត្រី០៥រូប ចូលរួមវគ្គ Programme on Leadership Engagement and Development LEAD វគ្គDiploma in Communication English and MS Office Skills នៅប្រទេសឥណ្ឌា និងមន្ត្រី០១រូបទៀត ចូលរួមវគ្គសហគមន៍សង្គម នៅប្រទេសជប៉ុន ។

**៨.ការអភិវឌ្ឍស្ថាប័ន៖**

-ធានាការរៀបចំអាសនៈក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍ សម័យប្រជុំពេញអង្គ ការបង្កើតលេខាធិការដ្ឋានគណៈកម្មការទី១០ ការិយាល័យសមាជិកព្រឹទ្ធសភា បន្ទប់ប្រជុំគណៈកម្មការទី១០ ។

-ផ្តល់ធនធាន មធ្យោបាយ និងការរៀបចំផ្សេងៗស្របតាមការប្រែប្រួលថ្មី ។

**៩. ការងារផ្ទៃក្នុង សន្តិសុខ ធនធាន មធ្យោបាយ ទីកន្លែង៖**

-ការបង្កើតគណៈកម្មការជំរឿននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងចុះធ្វើជំរឿនមន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា និងអ្នកហាត់ការ ។

-ពង្រឹងការអនុវត្តបទបញ្ជាផ្ទៃក្នុងរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អនុវត្តវិន័យ និងរបបរាយការណ៍វត្តមានទៀងទាត់ប្រាកដប្រជា ។

-ធ្វើសេចក្តីសម្រេចពាក់ព័ន្ធនឹងការកែសម្រួលក្បាលម៉ាស៊ីនព្រឹទ្ធសភា ក្នុងវង្វង់គណៈកម្មាធិការអចិន្ត្រៃយ៍ គណៈកម្មការនានា ក្រុមសមាជិកព្រឹទ្ធសភា ក្រុមភូមិភាគ ក្រុមមិត្តភាព៥ក្រុម ក្រុមAIPA, IPU, APF, CLV ក្រុមសមាជិកាព្រឹទ្ធសភា ។

-បើកប្រាក់ឧបត្ថម្ភបុណ្យភ្ជុំបិណ្ឌ និងប្រាក់បៀវត្សជូនសមាជិកព្រឹទ្ធសភា មន្ត្រីរាជការ បានទាន់ពេលវេលា ។

-ផ្សព្វផ្សាយអាហារូបករណ៍ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកនីតិសាស្ត្រ សិក្សានៅប្រទេសជប៉ុន ។

-រៀបចំដំណើរការប្រឡងប្តូរប្រភេទក្របខ័ណ្ឌមន្ត្រីរាជការ និងរៀបចំសេចក្តីសម្រេចតាំងស៊ប់ក្នុងមុខតំណែង ។

-ការបង្កើតគណៈកម្មការរៀបចំប្រទីបព្រឹទ្ធសភា ។

-អង្គភាពសន្តិសុខផ្ទៃក្នុងព្រឹទ្ធសភា បានចាត់កងកម្លាំងការពារសន្តិសុខ សណ្តាប់ធ្នាប់ ក្នុងកិច្ចប្រជុំ និងពិធីផ្សេងៗ ចំនួន០៩លើក ។

-ថតចម្លងឯកសារ ចំនួន១៥៩សំណើ ចងក្រងឯកសារជាសៀវភៅ ចំនួន២៧ក្បាល ដោះស្រាយសំណើថវិកាចំនួន៣៣២សំណើ និងសម្ភារចំនួន២៨សំណើ ព្រមទាំងផ្តល់សេវាដឹកជញ្ជូនចំនួន១០៩លើក ។

-ប្រគល់ម៉ាស៊ីនត្រជាក់ ម៉ាស៊ីនហ្វូតូកូពី ទូរទស្សន៍ តុដែក ទូដែកដាក់ឯកសារ កៅអីពូកទឹកមាស កៅអីវិល សាឡុង ចំនួន៣៨គ្រឿង បំពាក់ទូរទស្សន៍ នាឡិកា ចំនួន០៣គ្រឿង និងបិទលេខកូដតុដែក កៅអីវិល ទូដែកដាក់ឯកសារ ចំនួន១៩គ្រឿង ។ បញ្ចូលហ្គាស ជួសជុល ម៉ាស៊ីនត្រជាក់ បន្ទប់ទឹក ទូទឹកកក ទូរស័ព្ទ ប្តូរអំពូល ព្រី កុងតាក់ សោទ្វារ ចំនួន១០៦គ្រឿង ។

-ជួសជុលកុំព្យូទ័រ ត្រួតពិនិត្យ បញ្ចូលកម្មវិធីកំចាត់មេរោគ Update Files Antivirus បញ្ចូលកម្ម

វិធីខ្មែរ Unicode, Office ចុះតាមដាន Internet និង Network សរុបចំនួន៤២គ្រឿង និងបាន Upload ព័ត៌មាន និងឯកសារផ្សេងៗ ចំនួន៦៦ប្រធានបទ ។

**II.ទិសដៅការងារខែតុលា ឆ្នាំ២០១៤**

**១.សេវាទ្រទ្រង់មុខងារនីតិកម្ម៖**

-ត្រៀមរៀបចំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងប្រជុំវិសាមញ្ញ ព្រឹទ្ធសភា (ប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍លើកទី១ ថ្ងៃទី០៣ តុលា, ប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍លើកទី២ ថ្ងៃទី០៩ តុលា និងសម័យប្រជុំវិសាមញ្ញ ថ្ងៃទី១០ តុលា) ។

**២.សេវាទ្រទ្រង់មុខងារត្រួតពិនិត្យ/ ព័ត៌មាន៖**

-ត្រៀមសម្រួលការជួបសវនាការរវាងគណៈកម្មការជំនាញ និងក្រសួងស្ថាប័ននានា និងការចុះបេសកកម្មតាមបណ្តាខេត្ត ។

**៣.សេវាទ្រទ្រង់មុខងារតំណាង៖**

-ការរៀបចំវេទិកាសាធារណៈរបស់ក្រុមសមាជិកព្រឹទ្ធសភា តាមភូមិភាគ រួមទាំងវេទិកាក្រុមសមាជិកាព្រឹទ្ធសភា ។

**៤.ការងារអន្តរជាតិ៖**

-ត្រៀមរៀបចំពិធីជំនួបរវាងថ្នាក់ដឹកនាំជាមួយគណៈប្រតិភូបរទេស និងអគ្គទូតនានា។

-គណៈប្រតិភូអនុប្រធានសភា ក្រុមប្រឹក្សាពិគ្រោះយោបល់ប្រជាជនចិន (ខែធ្នូ) ។

-ត្រៀមរៀបចំបែបបទជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា បំពេញបេសកកម្មក្រៅប្រទេស រួមទាំងអគ្គលេខាធិការដ្ឋាន៖

-ការចូលរួមមហាសន្និបាតIPU ។

-បន្តយុទ្ធនាការស្វែងរកការគាំទ្រ និងជំនួយពីប្រភពក្នុង/ក្រៅប្រទេស សំរាប់ព្រឹទ្ធសភាតាមរយៈវិទ្យាស្ថានសភាកម្ពុជា ។

-ការចុះហត្ថលេខាលើឯកសារផ្តល់ជំនួយ និងកិច្ចសហប្រតិបត្តិការជាមួយរដ្ឋាភិបាលស៊ុយអែតស្វីស និងរដ្ឋសភាបាពាំង ទន្ទឹមនឹងការងារPBO ជាមួយសហគមន៍អឺរ៉ុប និងធនាគារពិភពលោក។ ការដ្ឋានសហប្រតិបត្តិការជាមួយចិន និងវៀតណាម ទន្ទឹមនឹងសិក្សាលទ្ធភាពថ្មីជាមួយជប៉ុន ។

**៥.ការអភិវឌ្ឍន៍ធនធានមនុស្ស៖**

-ជំរុញលើកកម្ពស់ចំណេះដឹង ជំនាញភាសាបរទេស និងបច្ចេកវិទ្យាព័ត៌មាន និងយកចិត្តទុកដាក់ដល់ការពង្រឹងវិន័យ និងសណ្តាប់ធ្នាប់សាធារណៈ ។

**៦.ការងារផ្ទៃក្នុង សន្តិសុខ ធនធាន មធ្យោបាយ ទីកន្លែង៖**

-ត្រៀមចូលរួមពិធីបុណ្យជាតិសំខាន់ៗក្នុងខែតុលា និងវិច្ឆិកា : រួមទាំងទិវាសិទ្ធិមនុស្ស នាខែធ្នូ

ខាងមុខ ។

-ត្រៀមសិក្ខាសាលាជាមួយ UNESCO (០៣ តុលា) និងជាមួយ KAF (វិច្ឆិកា ) ។

-បន្តតាមដានគម្រោងថវិកា ឆ្នាំ២០១៥ របស់ព្រឹទ្ធសភា ដែលត្រូវឆ្លងគណៈ រដ្ឋមន្ត្រី និងរដ្ឋសភា ។

-សិក្សាអំពីការដាក់ឲ្យអនុវត្តអង្គភាពថវិកា សម្រាប់០២អង្គភាព ជាជំហានដំបូង ។

-បន្តពង្រឹងដំណើរការកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងជំរុញដំណើរការរបស់អង្គភាពសវនកម្មផ្ទៃក្នុង ។

-ត្រៀមរបាយការណ៍គ្រប់ថ្នាក់ប្រចាំឆ្នាំ រួមទាំងរបាយការណ៍ហិរញ្ញវត្ថុឆ្នាំ២០១៤ និងគោលការណ៍ហិរញ្ញវត្ថុសំរាប់អនុវត្ត ឆ្នាំ២០១៥ ។

-គិតគូរអំពីការប្រឡងផ្ទេរក្របខ័ណ្ឌ ការតាំងស៊ប់ក្នុងមុខតំណែង ការផ្តល់គ្រឿងឥស្សរិយយសដល់មន្ត្រីរាជការ ការបំពេញបន្ថែមតំរូវការរបស់អគ្គនាយកដ្ឋានសេវាច្បាប់/សមូហភាពដែនដី និងអគ្គនាយកដ្ឋានព័ត៌មាន និងទំនាក់ទំនងសាធារណៈ បន្តនីតិវិធីតែងតាំងអគ្គលេខាធិការរង០១រូប ។

-ការត្រៀមប្រជុំអំពីនីតិវិធីអនុវត្តបទបញ្ជាផ្ទៃក្នុង និងក្របខ័ណ្ឌយុទ្ធសាស្ត្រ១០ឆ្នាំ របស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋាន ។

-បង្កើនសមត្ថភាពស្រាវជ្រាវអំពីឯកសារ ការចងបណ្តាញនាយកដ្ឋាន និងអង្គភាព និងចងក្រងទិន្នន័យបច្ចុប្បន្នភាពរបស់ជាតិ ដើម្បីពង្រឹងសមត្ថភាពស្រាវជ្រាវ និងផ្តល់សេវា ។

-ការជំរឿនធនធាន មធ្យោបាយ និងទ្រព្យសម្បត្តិ ការងារសំណង់/ ជួសជុលក្នុងពេលវិស្សមកាលព្រឹទ្ធសភា ។

-ត្រៀមការបោះពុម្ពដំណាច់ឆ្នាំ និងរៀបចំប្រទីប ។

## III.សេចក្តីសន្និដ្ឋាន

ក្នុងខែកញ្ញានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍បន្តសម័យប្រជុំពេញអង្គលើកទី៥ ដើម្បីបោះឆ្នោតជ្រើសតាំងសមាជិកគណៈកម្មការថ្មី (គណៈកម្មការទី១០) និងបោះឆ្នោតជ្រើសរើសបំពេញសមាជិកគណៈកម្មការទី១, ទី៣, ទី៦, ទី៧, ទី៨ និងគណៈកម្មការទី៩ ព្រឹទ្ធសភា និងបោះឆ្នោតជ្រើសតាំងសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមចំនួន០១រូប ។ ការងារលេចធ្លោគឺការរៀបចំវេទិកា ចំនួន០៥លើក នៅខេត្តប៉ៃលិន ត្បូងឃ្មុំ កណ្តាល ព្រះវិហារ និងខេត្តស្វាយរៀង ។ ក្រុមនានា ត្រូវបានកែសម្រួល និងបំពេញបន្ថែមតួនាទី ភារកិច្ច និងសមត្ថភាព ។ តួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់គណៈកម្មការទី១០ ត្រូវបានកំណត់ ។

ខែកញ្ញាជាខែនៃការអនុវត្តកិច្ចព្រមព្រៀង៥ចំណុចនៃដំណោះស្រាយនយោបាយពាក់ព័ន្ធនឹង

ព្រឹទ្ធសភា ។ អ្វីៗបានដំណើរការដោយរលូន និងគ្រប់ជ្រុងជ្រោយ ។

ព្រឹទ្ធសភាបានបញ្ចប់សម័យប្រជុំលើកទី៩ ដោយមានលទ្ធផលល្អលើសសម័យប្រជុំមុនៗ ។

សមត្ថភាពផ្តល់ពហុសេវារបស់អគ្គលេខាធិការដ្ឋាន ប្រព្រឹត្តទៅដោយសកម្ម រលូន និងមានលទ្ធផលជាផ្លែផ្កា ។

ភ្នំពេញ,ថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៥

**អគ្គលេខាធិការ**

**អ៊ុំ សារិទ្ធ**